២៨.	ឯកឧត្តម ឈួន ចាន់ថន អនុប្រធាននៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងកេរវកម្ម	សមាជិក

ប្រការ ២.-

គណៈកម្មការជាតិនេះ មានភារកិច្ចដូចតទៅ៖

- សម្របសម្រួល ចាត់ចែង ពិគ្រោះយោបល់ និងត្រួតពិនិត្យដំណើរការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ លើកទី៤១ និងកិច្ចប្រជុំពាក់ព័ន្ធ អំឡុងពេលកម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២២ ឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ
- លើកគម្រោងចំណាយសរុបសម្រាប់ការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ លើកទី៤១ និងកិច្ចប្រជុំពាក់ព័ន្ធ សម្រាប់កម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២២ ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល
- សម្របសម្រួល និងផ្តល់អនុសាសន៍ដល់លេខាធិការដ្ឋានជាតិអាស៊ាន-កម្ពុជា ក្រុមការងារសម្របសម្រួល និងអនុគណៈកម្មការនានា

- ចូលរួមកិច្ចប្រជុំរួម នៃតំណាងជាតិទាំងបីសម្រាប់ក្រុមប្រឹក្សាកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ក្រុមប្រឹក្សាកិច្ចការសហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន
- ចូលរួមកិច្ចប្រជុំរួមនៃលេខាធិការដ្ឋានជាតិទាំងបីសម្រាប់ក្រុមប្រឹក្សាកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ក្រុមប្រឹក្សាកិច្ចការសហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន
- ស្នើសុំអនុសាសន៍ណែនាំ និងគោលការណ៍សម្រេចពី **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**
- ធ្វើរបាយការណ៍វឌ្ឍនភាពជាប្រចាំគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**។

ប្រការ ៣.-

គណៈកម្មការជាតិនេះមាន លេខាធិការដ្ឋានមួយសម្រាប់ធ្វើការងារសម្របសម្រួល និងអនុគណៈកម្មការចំនួន ៦ ជាសេនាធិការ រួមមាន៖

- លេខាធិការដ្ឋាន
- អនុគណៈកម្មការទី១៖ ខ្លឹមសារ និងឯកសារ
- អនុគណៈកម្មការទី២៖ ពិធីការ និងបដិសណ្ឋារកិច្ច
- អនុគណៈកម្មការទី៣៖ ហិរញ្ញវត្ថុ
- អនុគណៈកម្មការទី៤៖ សន្តិសុខ និងសណ្តាប់ធ្នាប់ និងសង្គ្រោះបឋម
- អនុគណៈកម្មការទី៥៖ សារព័ត៌មាន និងផ្សព្វផ្សាយ
- អនុគណៈកម្មការទី៦៖ កិច្ចប្រជុំ និងព្រឹត្តិការណ៍អម (Side-Events)។

ប្រការ ៤.-

សមាសភាព តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន និងអនុគណៈកម្មការទាំង ៦ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មការជាតិ។

លេខាធិការដ្ឋាន និងអនុគណៈកម្មការនានា ត្រូវរៀបចំផែនការការងារលម្អិត និងកាលវិភាគជាក់លាក់រៀងៗខ្លួន បង្កើតក្រុមការងារជំនាញតាមការចាំបាច់ ធ្វើរបាយការណ៍ជូនគណៈកម្មការជាតិជាប្រចាំ និងទទួលអនុវត្តការងារតាមការណែនាំរបស់គណៈកម្មការជាតិ។

ប្រការ ៥.-

គណៈកម្មការជាតិនេះ មានសិទ្ធិប្រើប្រាស់ត្រា និងលិខិតមានក្បាលដែលមានសញ្ញាសម្គាល់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីដំណើរការការងាររបស់ខ្លួន។

ប្រការ ៦.-

គណៈកម្មការជាតិនេះ ប្រើប្រាស់កញ្ចប់ថវិកាដោយឡែក ដើម្បីដំណើរការការងាររបស់ខ្លួន និងមានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន ព្រមទាំងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីជួយទ្រទ្រង់ និងឧបត្ថម្ភការងារត្រៀមរៀបចំមុន និងក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ លើកទី៤១ និងកិច្ចប្រជុំពាក់ព័ន្ធ អំឡុងពេលកម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២២។

ថវិកាសម្រាប់រៀបចំកិច្ចប្រជុំ និងព្រឹត្តិការណ៍អម (side-events) ជាបន្ទុករបស់ក្រសួង-ស្ថាប័នដែលទទួលរៀបចំ។

ប្រការ ៧.-

គណៈកម្មការជាតិនេះ នឹងត្រូវបញ្ចប់ការកិច្ចរបស់ខ្លួនដោយស្វ័យប្រវត្តិនៅពេលកម្ពុជាចប់អាណត្តិធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០២២។

ប្រការ ៨.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្ជឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៩.-

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឬា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប: រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង-ប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦ កើត ខែកាត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ឧទ្ធកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ឧទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៩
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តមកពីរាជកិច្ចលេខ ៧៧

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១.....សហវ.....

ថ្ងៃ..... ខែ..... ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ..... ខែ..... ឆ្នាំ ២០១៩

ប្រកាស
ស្តីពី
ការប្រគល់ភាពឯកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាល
សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃ សុក្រ ០៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃ សុក្រ ០២កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមដំណាក់នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

សម្រេច

ប្រការ១ ._

ឥណទានចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ត្រូវបានបែងចែកលម្អិតតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដូចមានចែងក្នុងសៀវភៅថវិកា ដែលភ្ជាប់នឹងប្រកាសនេះ។

ប្រការ២ ._

រដ្ឋមន្ត្រីគ្រប់ក្រសួង នាយកគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

ប្រការ៣ ._

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២០។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ៉ា

ចម្លងជូន៖
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង–រដ្ឋលេខាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានថវិកា
នាយកដ្ឋានថវិកានីយកម្ម

ការគ្រប់គ្រងឆ្នាំ ២០២០

ចំណូល ចំណាយថវិកាកម្មវិធីគ្រឹះស្ថានសាធារណៈរដ្ឋបាល

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានថវិកា

ការគ្រប់គ្រងឆ្នាំ ២០២០
ឥណទានចំណូលថវិការគ្រឹះស្ថានសាធារណៈរដ្ឋបាល
មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយឥណទាននិងសារៀបរៀងថវិកា ឯកតា: លានរៀល

ជំពូក	មាត្រា	ទំហំរងរ	ចំណាត់ថ្នាក់ចំណូល	ចំណូលប្រចាំឆ្នាំ	សេចក្តីផ្សេងៗ
សរុបរួមចំណូលថវិកា (ក+ខ)				5.175,0	
ក.សរុបចំណូលចរន្ត (ក្រុមធី១ + ក្រុមធី២)				5.175,0	
ក្រុមធី១ : ចំណូលពន្ធ				5.175,0	
ប្រភេទធី ២ : ចំណូលមិនមែនសារពើពន្ធ				5.175,0	
73			ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា	4.070,0	
	7308		ផលពីការគ្រប់គ្រងរដ្ឋបាល (2)	4.070,0	
		73087	ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការការពារបរិយាកាស	4.070,0	
75			ការទូទាត់ត្រឡប់ និង រំលោះ	1.105,0	
	7501		ទុនត្រឡប់ធនពីថ្នាក់ជាតិ	843,0	
		75011	ទុនត្រឡប់ធនពីក្រសួង-ស្ថាប័ន	843,0	
	7510		មូលនិធិបំរុង	262,0	
		75101	អតិរេកនៃការិយបរិច្ឆេទ	262,0	

ឧបសម្ព័ន្ធ ១

ការគ្រប់គ្រងឆ្នាំ ២០២០
ចំណាយថវិកាតាមចំណាត់ថ្នាក់កម្មវិធី និងតាមអនុតាពថវិកា
មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ឯកតា÷លានរៀល

កម្មវិធី អនុកម្មវិធី និងមេក្លោមសកម្មភាព	សរុបវិភាគទាន	ចំណាត់ថ្នាក់មុខងារ	អង្គភាពចំណាយទូលនុសញ្ញា
៤.កម្មវិធីធំ ៤ ÷ ពង្រឹងប្រព័ន្ធសុខាភិបាល	5.175,0		
៤.១.អនុកម្មវិធី ១ ៖ ការផ្តល់សេវាសុខាភិបាល	3.343,0		120607- មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល
៤.១.៥.ច.សកម្ម ៥ ៖ ធានាឲ្យមានវិសជ-បរិក្ខារគ្រប់គ្រាន់ និងទាន់ពេលវេលានៅតាមមណ្ឌលសុខភាព និងបន្ទប់ពេទ្យបង្អែក	1.400,0	70711	
៤.១.១៣.ច.សកម្ម ១៣ ៖ ធានាការផ្តត់ផ្គង់ម្សៃភ្លើបាល សំភារៈជាមូលដ្ឋានសម្រាប់ពង្រឹងដំណើរការផ្តល់សេវា ស.ស.អ និង ស.ស.ប	995,0	70731= 59,7% 70760= 40,3%	
៤.១.១៤.ច.សកម្ម ១៤ ៖ ធានាការជួសជុលថែទាំ សំភារៈជាមូលដ្ឋាន ប្រចាំឆ្នាំ ហេដ្ឋារចនាសម្ព័ន្ធ សំណង់ដំណើរការផ្តល់សេវា ស.ស.អ និង ស.ស.ប	544,0		
៤.១.២៦.ច.សកម្ម ២៦ ៖ សុខដុមនីយកម្ម និងការតម្រៀបតម្រង់នៅក្រសួងសុខាភិបាល និងទូទាំងវិស័យ	404,0		
៤.៣.អនុកម្មវិធី ៣ ៖ អភិវឌ្ឍន៍ធនធានមនុស្ស	1.832,0		120607- មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល
៤.៣.២២.ច.សកម្ម ២២ ៖ បែងចែក និងការអភ្ជាប់ធនធានមនុស្ស ផ្តល់ភាពជាប់ឃ្លាតដែលត្រូវការចាំបាច់សម្រាប់ អាទិភាពវិស័យសុខាភិបាល	1.832,0	70760	

ការគ្រប់គ្រងឆ្នាំ ២០២០

ចំណាយថវិកាតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងតាមជំពូក

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ឯកតា÷លានរៀល

កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព	សរុបចំណាយ ឬកាតព្វកិច្ច	ចំណាយចរន្ត						
		សរុប	ជំពូក៦០	ជំពូក៦១	ជំពូក៦៤	ជំពូក៦២	ជំពូក៦៥	ជំពូក៦៣
៤.កម្មវិធីធំ ៤ ÷ តម្លៃចម្លងតំនុសុខាភិបាល	5.175,0	5.175,0	2.395,0	1.136,0	1.472,0		169,0	3,0
៤.១.អនុកម្មវិធីទី ១ ៖ ការផ្តល់សេវាសុខាភិបាល	3.343,0	3.343,0	2.395,0	776,0			169,0	3,0
៤.១.៩.ច.សទី ៩ ៖ ជានាឲ្យមានវិសជ-បរិក្ខារគ្រប់គ្រាន់ និងទាន់ពេលវេលានៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក	1.400,0	1.400,0	1.400,0					
៤.១.១៣.ច.សទី ១៣ ៖ ជានាការផ្តត់ផ្គង់ផ្នែករដ្ឋបាល សំភារៈជាមូលដ្ឋានសម្រាប់ពង្រឹងដំណើរការផ្តល់សេវា ស.ស.អ និង ស.ស.ប	995,0	995,0	995,0					
៤.១.១៤.ច.សទី ១៤ ៖ ជានាការជួសជុលថែទាំ សំភារៈជាមូលដ្ឋាន រួមទាំងហេដ្ឋារចនាសម្ព័ន្ធសំរាប់ដំណើរការផ្តល់សេវា ស.ស.អ និង ស.ស.ប	544,0	544,0		544,0				
៤.១.២៦.ច.សទី ២៦ ៖ សុខដុមនីយកម្ម និងការតម្រៀបតម្រង់នៅក្រសួងសុខាភិបាល និងទ្ទាំងវិស័យ	404,0	404,0		232,0			169,0	3,0
៤.៣.អនុកម្មវិធីទី ៣ ៖ អភិវឌ្ឍន៍ធនធានមនុស្ស	1.832,0	1.832,0		360,0	1.472,0			
៤.៣.២២.ច.សទី ២២ ៖ បែងចែក និងការរក្សាទុកបុគ្គលិកដោយផ្តល់អាទិភាពដល់បុគ្គលិកដែលត្រូវការចាំបាច់សម្រាប់អាទិភាពវិស័យសុខាភិបាល	1.832,0	1.832,0		360,0	1.472,0			

ភាគទី ៣

ការត្រួតពិនិត្យឆ្នាំ ២០២០
ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី និងតាមជំពូក គណនី និងអនុគណនី
មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអភិក្រមឥណទាននិងសាច់ប្រាក់

ឯកតារូបិយប័ណ្ណ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយថវិកាកម្មវិធី	កម្មវិធីទី៤	
					៤.១.អនុកម្មវិធីទី១	៤.៣.អនុកម្មវិធីទី៣
សរុបរួមចំណាយថវិកា (ក+ខ)				5.175,0	3.343,0	1.832,0
ក. សរុបចំណាយចរន្ត (ក្រុមធំ១+ក្រុមធំ២)				5.175,0	3.343,0	1.832,0
ក្រុមធំ១ : ចំណាយពិត (ប្រភេទធំ១ + ប្រភេទធំ២ + ប្រភេទធំ៣ + ប្រភេទធំ៤)				5.175,0	3.343,0	1.832,0
ប្រភេទធំ១ : មធ្យោបាយ និងសេវា				5.003,0	3.171,0	1.832,0
60			ការងារ	2.395,0	2.395,0	
	6001		សម្ភារៈផ្គត់ផ្គង់ថែទាំ	110,0	110,0	
		60011	សម្ភារៈផ្គត់ផ្គង់សម្អាត និងអនាម័យ	40,0	40,0	
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	70,0	70,0	
	6002		សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល	83,0	83,0	
		60021	សម្ភារការិយាល័យ	50,0	50,0	
		60022	សៀវភៅមើល និងឯកសារ	10,0	10,0	
		60023	ការចោះពុម្ព	18,0	18,0	
		60028	សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ	5,0	5,0	
	6003		ស្បៀងអាហារ និងផលិតផលកសិកម្ម	45,0	45,0	
		60032	ចំណីសត្ว	40,0	40,0	
		60037	ស្បៀងសម្រាប់រដ្ឋបាល	5,0	5,0	
	6004		សំលៀកបំពាក់ និងការពុះពែង	27,0	27,0	
		60041	ឯកសណ្ឋាន	17,0	17,0	
		60042	សំលៀកបំពាក់ការពារសុវត្ថិភាព	10,0	10,0	
	6005		សម្ភារៈកូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ	150,0	150,0	
		60051	សម្ភារៈនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា	10,0	10,0	
		60052	សង្ហារឹម	90,0	90,0	
		60053	សម្ភារៈប្រើប្រាស់	10,0	10,0	
		60055	សម្ភារៈនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា	40,0	40,0	
	6006		ថាមពលនិងទឹក	570,0	570,0	
		60061	អគ្គិសនី	560,0	560,0	
		60062	ទឹក	10,0	10,0	
	6007		សម្ភារៈបរិក្ខារថែទាំសុខភាព	1.410,0	1.410,0	
		60071	ប៉ាន់ហ្គាសនិងអុកស៊ីសែន	10,0	10,0	
		60072	សម្ភារៈបរិក្ខារពេទ្យ	870,0	870,0	
		60078	សម្ភារៈបរិក្ខារថែទាំសុខភាពផ្សេងៗ	530,0	530,0	
61			សេវាកម្ម	1.136,0	776,0	360,0
	6101		កិច្ចសន្យាឧបការផ្តល់សេវាជាមួយសហគ្រាស	9,0	9,0	
		61011	សេវាអនាម័យ	9,0	9,0	
	6105		ការថែទាំនិងជួសជុល	544,0	544,0	

try Pil Ro

ការិយាល័យ ៣

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី និងតាមជំពូក គណនី និងអនុគណនី

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយវណ្ណទាននិងសាវ៉ាច្ចវ៉ា

ឯកតា៖ លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយថវិកាកម្មវិធី	កម្មវិធីទី៨	
					៨.១.អនុកម្មវិធីទី១	៨.៣.អនុកម្មវិធីទី៣
		61051	ការថែទាំដីធ្លី ស្មៅ ច្បារ ព្រៃឈើ តំបន់ផ្អេរ និងដែនទេសាន	5,0	5,0	
		61052	ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ	90,0	90,0	
		61054	ការថែទាំបណ្តាញផ្សេងៗ	200,0	200,0	
		61056	ការថែទាំ និងជួសជុលបណ្ដោយ ដែកជញ្ជូន	19,0	19,0	
		61057	ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស	60,0	60,0	
		61058	ការថែទាំនិងជួសជុលផ្សេងៗ	170,0	170,0	
	6108		**សោហ៊ុយដឹកជញ្ជូន**	4,0	4,0	
		61081	សម្ភារ និងទំនិញ	4,0	4,0	
	6109		**បុគ្គលិកខាងក្រៅ**	360,0		360,0
		61091	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	360,0		360,0
	6110		**ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ**	70,0	70,0	
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	10,0	10,0	
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	10,0	10,0	
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	30,0	30,0	
		61104	ចំណាយរៀបចំពិធីបុណ្យ	10,0	10,0	
		61105	ចំណាយសម្រាប់ដែនអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស	10,0	10,0	
	6112		**សោហ៊ុយបេសកកម្មក្នុងប្រទេស**	39,0	39,0	
		61121	សោហ៊ុយដឹកជញ្ជូន	9,0	9,0	
		61122	សោហ៊ុយបេសកកម្ម	15,0	15,0	
		61123	សោហ៊ុយស្នាក់នៅ	15,0	15,0	
	6113		**សោហ៊ុយបេសកកម្មក្រៅប្រទេស**	90,0	90,0	
		61131	សោហ៊ុយដឹកជញ្ជូន	25,0	25,0	
		61132	សោហ៊ុយបេសកកម្ម	20,0	20,0	
		61133	សោហ៊ុយស្នាក់នៅ	45,0	45,0	
	6114		**សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍**	15,0	15,0	
		61141	សោហ៊ុយប្រៃសណីយ៍	5,0	5,0	
		61142	សោហ៊ុយទូរគមនាគមន៍	10,0	10,0	
	6115		**សោហ៊ុយធនាគារ**	5,0	5,0	
		61151	សោហ៊ុយធនាគារ	5,0	5,0	
64			**បន្ទុកបុគ្គលិក**	1.472,0		1.472,0
	6402		**លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍**	60,0		60,0
		64028	ប្រាក់បំណាច់ការងារពិសេស និងហ៊ានលំបាកសុខភាព	60,0		60,0
	6403		**ប្រាក់បំណាច់ផ្សេងៗ**	1.412,0		1.412,0
		64033	រង្វាន់	1.292,0		1.292,0
		64037	ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន	120,0		120,0
ប្រភេទធនធាន : អន្តរាគមន៍សាធារណៈ				169,0	169,0	

ឧបសម្ព័ន្ធ ៣

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី និងតាមជំពូក គណនី និងអនុគណនី

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយសំណងទាននិងសោយធ្វើការ

ឯកតា៖លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយថវិកាកម្មវិធី	កម្មវិធីទី៨	
					៨.១.អនុកម្មវិធីទី១	៨.៣.អនុកម្មវិធីទី៣
65			ឧបត្ថម្ភធន	169,0	169,0	
	6502		ឧបត្ថម្ភធនដល់អង្គការសាធារណៈ	9,0	9,0	
		65028	ផ្សេងៗ	9,0	9,0	
	6506		វិភាគទានដល់អង្គការ សមាគម សហព័ន្ធអន្តរជាតិនានា	160,0	160,0	
		65068	អង្គការ សមាគម សហព័ន្ធអន្តរជាតិផ្សេងៗទៀត	160,0	160,0	
ប្រភេទគណនី៤ : ចំណាយផ្សេងៗ				3,0	3,0	
63			ពន្ធ និងអាករ	3,0	3,0	
	6301		លាបម្រ	3,0	3,0	
		63011	លាបម្រ	3,0	3,0	

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី ចក្ខោមសកម្មភាព និងតាមជំពូក គណនី និងអនុគណនី

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយតណ្ណាទាននិងសារប័ព្ទថវិកា

ឯកតា៖លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយថវិកាកម្មវិធី	កម្មវិធីទី៤						
					៤.១.អនុកម្មវិធីទី១					៤.៣.អនុកម្មវិធីទី៣	
					សរុប	ច.សទ្ធ	ច.សទ្ធ	ច.សទ្ធ	ច.សទ្ធ	សរុប	ច.សទ្ធ
សរុបរួមចំណាយទាំងអស់ (ក+ខ)				5.175,0	3.343,0	1.400,0	995,0	544,0	404,0	1.832,0	1.832,0
ក. សរុបចំណាយចរន្ត (ក្រុមទី១+ក្រុមទី២)				5.175,0	3.343,0	1.400,0	995,0	544,0	404,0	1.832,0	1.832,0
ក្រុមទី១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២ + ប្រភេទទី៣ + ប្រភេទទី៤)				5.175,0	3.343,0	1.400,0	995,0	544,0	404,0	1.832,0	1.832,0
ប្រភេទទី១ : មធ្យោបាយ និងសេវា				5.003,0	3.171,0	1.400,0	995,0	544,0	232,0	1.832,0	1.832,0
60			ការទិញ	2.395,0	2.395,0	1.400,0	995,0				
	6001		សម្ភារផ្គត់ផ្គង់ថែទាំ	110,0	110,0		110,0				
		60011	សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ	40,0	40,0		40,0				
		60015	ប្រេងឥន្ធនៈ និងប្រេងរំអិល	70,0	70,0		70,0				
	6002		សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល	83,0	83,0		83,0				
		60021	សម្ភារការិយាល័យ	50,0	50,0		50,0				
		60022	សៀវភៅមើល និងឯកសារ	10,0	10,0		10,0				
		60023	ការបោះពុម្ព	18,0	18,0		18,0				
		60028	សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ	5,0	5,0		5,0				
	6003		ស្បៀងអាហារ និងផលិតផលកសិកម្ម	45,0	45,0		45,0				
		60032	ចំណីសត្ត	40,0	40,0		40,0				
		60037	ស្បៀងសម្រាប់រដ្ឋបាល	5,0	5,0		5,0				
	6004		សំលៀកបំពាក់ និងការកុបតែង	27,0	27,0		27,0				

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងតាមជំពូក គណនី និងអនុគណនី

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយតំណាងនិងសារៀបចំវិកា

ឯកតា៖លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយថវិកាកម្មវិធី	កម្មវិធីទី៤						
					៤.១.អនុកម្មវិធីទី១					៤.៣.អនុកម្មវិធីទី៣	
					សរុប	ច.សទ្ធ	ច.សទ្ធ១៣	ច.សទ្ធ១៨	ច.សទ្ធ២៦	សរុប	ច.សទ្ធ២១
		60041	ឯកសណ្ឋាន	17,0	17,0		17,0				
		60042	សំលៀកបំពាក់ការពារសុវត្ថិភាព	10,0	10,0		10,0				
	6005		សម្ភារក្នុងតាង សង្ហារឹម និងសម្ភារបរិក្ខារ	150,0	150,0		150,0				
		60051	សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា	10,0	10,0		10,0				
		60052	សង្ហារឹម	90,0	90,0		90,0				
		60053	សម្ភារប្រើប្រាស់	10,0	10,0		10,0				
		60055	សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា	40,0	40,0		40,0				
	6006		ថាមពលនិងទឹក	570,0	570,0		570,0				
		60061	អគ្គិសនី	560,0	560,0		560,0				
		60062	ទឹក	10,0	10,0		10,0				
	6007		សម្ភារបរិក្ខារថែទាំសុខភាព	1.410,0	1.410,0	1.400,0	10,0				
		60071	បំពង់ហ្គាសនិងអុកស៊ីសែន	10,0	10,0		10,0				
		60072	សម្ភារបរិក្ខារពេទ្យ	870,0	870,0	870,0					
		60078	សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ	530,0	530,0	530,0					
61			សេវាកម្ម	1.136,0	776,0			544,0	232,0	360,0	360,0
	6101		កិច្ចសន្យានៃការផ្តល់សេវាជាអ្វយសហគ្រាស	9,0	9,0				9,0		
		61011	សេវាអនាម័យ	9,0	9,0				9,0		
	6105		ការថែទាំនិងជួសជុល	544,0	544,0			544,0			

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី ចម្លោមសកម្មភាព និងតាមជំពូក គណនី និងអនុគណនី

មជ្ឌមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយតណ្ហាទាននិងសារប័ព្ធ៧រ៉ាកា

ឯកតា៖លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយ ២ភាគកម្មវិធី	កម្មវិធីទី៤						
					៤.១.អនុកម្មវិធីទី១					៤.៣.អនុកម្មវិធីទី៣	
					សរុប	ច.សទ្ធ១	ច.សទ្ធ១៣	ច.សទ្ធ១៨	ច.សទ្ធ២៦	សរុប	ច.សទ្ធ២៦
		61051	ការថែទាំដីធ្លី ស្ងួតច្សារ ព្រៃឈើ តំបន់ឆ្នេរ និងដែនទេសាទ	5,0	5,0			5,0			
		61052	ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ	90,0	90,0			90,0			
		61054	ការថែទាំបណ្តាញផ្សេងៗ	200,0	200,0			200,0			
		61056	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	19,0	19,0			19,0			
		61057	ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស	60,0	60,0			60,0			
		61058	ការថែទាំនិងជួសជុលផ្សេងៗ	170,0	170,0			170,0			
	6108		**សោហ៊ុយដឹកជញ្ជូន**	4,0	4,0				4,0		
		61081	សម្ភារ និងទំនិញ	4,0	4,0				4,0		
	6109		**បុគ្គលិកខាងក្រៅ**	360,0						360,0	360,0
		61091	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	360,0						360,0	360,0
	6110		**ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ**	70,0	70,0				70,0		
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	10,0	10,0				10,0		
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	10,0	10,0				10,0		
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	30,0	30,0				30,0		
		61104	ចំណាយរៀបចំពិធីបុណ្យ	10,0	10,0				10,0		
		61105	ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស	10,0	10,0				10,0		
	6112		**សោហ៊ុយបេសកកម្មក្នុងប្រទេស**	39,0	39,0				39,0		
		61121	សោហ៊ុយដឹកជញ្ជូន	9,0	9,0				9,0		

ភាគទី ៤

ការគ្រប់គ្រងឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី ចក្ខោមសកម្មភាព និងតាមជំពូក គណនី និងអនុគណនី

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយតំណាងនិងសារៀបចំវិកា

ឯកតា៖លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយវិភាគកម្មវិធី	កម្មវិធីទី៤						
					៤.១.អនុកម្មវិធីទី១					៤.៣.អនុកម្មវិធីទី៣	
					សរុប	ច.សទ្ធី៩	ច.សទ្ធី១៣	ច.សទ្ធី១៨	ច.សទ្ធី២៦	សរុប	ច.សទ្ធី១២
		61122	សោហ៊ុយបេសកកម្ម	15,0	15,0				15,0		
		61123	សោហ៊ុយស្នាក់នៅ	15,0	15,0				15,0		
	6113		សោហ៊ុយបេសកកម្មក្រៅប្រទេស	90,0	90,0				90,0		
		61131	សោហ៊ុយដឹកជញ្ជូន	25,0	25,0				25,0		
		61132	សោហ៊ុយបេសកកម្ម	20,0	20,0				20,0		
		61133	សោហ៊ុយស្នាក់នៅ	45,0	45,0				45,0		
	6114		សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍	15,0	15,0				15,0		
		61141	សោហ៊ុយប្រៃសណីយ៍	5,0	5,0				5,0		
		61142	សោហ៊ុយទូរគមនាគមន៍	10,0	10,0				10,0		
	6115		សោហ៊ុយធនាគារ	5,0	5,0				5,0		
		61151	សោហ៊ុយធនាគារ	5,0	5,0				5,0		
64			ចន្ទុកបុគ្គលិក	1.472,0						1.472,0	1.472,0
	6402		លាភការនិងប្រាក់បំណាច់ បុគ្គលិកក្រៅបន្ទាត់ថ្នាក់ជាតិ	60,0						60,0	60,0
		64028	ប្រាក់បំណាច់ការងារចន្ទ និងបិះពាល់សុខភាព	60,0						60,0	60,0
	6403		ប្រាក់បំណាច់ផ្សេងៗ	1.412,0						1.412,0	1.412,0
		64033	រង្វាន់	1.292,0						1.292,0	1.292,0
		64037	ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់ត្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់អង្គភាពជនៃទៀត	120,0						120,0	120,0

ការភ្ជាប់ទី ៤

ការត្រួតពិនិត្យឆ្នាំ ២០២០

ការបែងចែកចំណាយតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងតាមជំពូក គណនី និងអនុគណនី

មជ្ឌលណ្ឌលជាតិពិសោធន៍សុខាភិបាល

ការអធិប្បាយវណ្ណទាននិងសារវ៉ាត់ចាក់ ឯកតា៖លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	សរុបចំណាយ ១ឆ្នាំ	កម្មវិធីទី៤						
					៤.១.អនុកម្មវិធីទី១					៤.៣.អនុកម្មវិធីទី៣	
					សរុប	ច.សទ្ធ.ជ	ច.សទ្ធ.ជ	ច.សទ្ធ.ជ	ច.សទ្ធ.ជ	សរុប	ច.សទ្ធ.ជ
ប្រភេទទី៣ : អន្តរាគមន៍សាធារណៈ				169,0	169,0				169,0		
65			ឧបត្ថម្ភធន	169,0	169,0				169,0		
	6502		ឧបត្ថម្ភធនដល់អង្គការសាធារណៈ	9,0	9,0				9,0		
		65028	ផ្សេងៗ	9,0	9,0				9,0		
	6506		វិភាគទានដល់អង្គការ សមាគម សហព័ន្ធអន្តរជាតិនានា	160,0	160,0				160,0		
		65068	អង្គការ សមាគម សហព័ន្ធអន្តរជាតិផ្សេងៗទៀត	160,0	160,0				160,0		
ប្រភេទទី៤ : ចំណាយផ្សេងៗ				3,0	3,0				3,0		
63			ពន្ធ និងអាករ	3,0	3,0				3,0		
	6301		លាបំត្រ	3,0	3,0				3,0		
		63011	លាបំត្រ	3,0	3,0				3,0		

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ...

ថ្ងៃ.....ខែ.....ឆ្នាំ.....
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....ខែ.....ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងសំណើសុំប្តូរវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន ហូលលី វ៉ែល ហ៊ីនប៊ីក មេនូហ្វេកធ័រីង ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ហូលលី វ៉ែល ហ៊ីនប៊ីក មេនូហ្វេកធ័រីង ឯ.ក (WHOLLY WELL HANDBAGS MANUFACTURING COMPANY LIMITED.) តំណាងដោយ លោក MO ZIXIANG បង្កើតរោងចក្រផលិតកាបូបគ្រប់ប្រភេទ និងខ្សែក្រវាត់ ដែលមានទីតាំងស្ថិតនៅ ភូមិអណ្តូង ឃុំមែកជាន ស្រុកអង្គស្នួល ខេត្តកណ្តាល។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
១-កាបូបគ្រប់ប្រភេទ	១៥១២
២-ខ្សែក្រវាត់	១៤១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតកាបូបគ្រប់ប្រភេទ និងខ្សែក្រវាត់ ហូលលី វ៉ែល ហ៊ែនវ៉ែក មេនូហ្ស្រេកធ្វីរ៉ែង ឯ.ក "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤: ប្រកាសបង្កើតរោងចក្រលេខ ០៤៦ ឧស.ក.ឧ.ប្រក.០២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩, លិខិតលេខ ៤២១៨ ឧស.ក.ឧ.លស.១០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៩ ស្តីពីការប្តូរប្រធានក្រុមប្រឹក្សាកិចាល និងលិខិតលេខ ៥៣០៩ ឧស.ក.ឧ.លស.១២ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការពង្រីកបន្ថែមមុខសញ្ញាផលិតកម្មផលិតខ្សែក្រវ៉ាត់ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ហ្ស៊ីង សុភា

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានពាណិជ្ជកម្ម និងសេវាកុំព្យូទ័រ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកណ្តាល
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល
-អាជ្ញាធរស្រុកអង្គស្នួល
-អាជ្ញាធរឃុំបែកចាន
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ ១០៥.....ក.ស.ភ.ស.ក.ម.ក.ម

ថ្ងៃ.....ខ.....ខ.....ឆ្នាំ.....ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....ខ.....ឆ្នាំ២០២០

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/ ០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ៣៥០៦/១៩ គ.វ.ក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្រោមខ្នើយ និងស្រោមពូក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រុមហ៊ុន សាន់រ៉ាយ ហ្វេសិន (ខេមបូឌា) ឯ.ក

ស ម្រេ ច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន សាន់រ៉ាយ ហ្វេសិន (ខេមបូឌា) ឯ.ក (SUNRISE FASHION (CAMBODIA) CO., LTD.) តំណាងដោយ លោកស្រី WANG, LILI បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្រោមខ្នើយ និងស្រោមពូក ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៣ ភូមិត្រពាំងឈូក ឃុំពោធិ៍អង្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
១-សម្លៀកបំពាក់	១៤១០
២-ស្រោមខ្នើយ និងស្រោមពូក	១៣៩២

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ ស្រោមខ្នើយ និងស្រោមពូក សាន់ប៉ាយ ហ្វេសិន (ខេមបូឌា) ឯ.ក "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្ម គ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមដំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្ម ច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
ជ្រើសរើសការិយាធិការ

ហាន សុតា

ទទួលខុសនៃ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរដ្ឋកិច្ច និងសេវាកុំព្យូទ័រ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ
-អង្គបាលស្រុកបរសេដ្ឋ
-អង្គបាលឃុំពោធិ៍អង្ក្រង
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៨ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៣២.រ.ម.#ប្រក.ប្រក

ប្រកាស
ស្តីពី
លក្ខខណ្ឌនៃលិខិតអនុញ្ញាតជំណើរការស្ថានីយប្រេងឥន្ធនៈ
លេខ.០០៣២.រ.ម.#ប្រក.លអ.....ចុះថ្ងៃទី...០៣.....ខែ..កុម្ភៈ.....ឆ្នាំ ២០២០.

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួម លេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រកចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់នៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល

- បានឃើញសារាចរលេខ០១៨០ រថ.អប្រក.សរចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំ ស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ របស់លោក **តាន់ តាត់**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈយីហោ **ភីធីធី សេតេ**(PTT CT) ស្ថិតនៅភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ របស់លោក **តាន់ តាត់** (ម្ចាស់ស្ថានីយ)។

ប្រការ២.

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយ នៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

ប្រការ៣.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៨១ រថ.អប្រក.ប្រកចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពលដោយត្រូវបំពេញបន្ថែម នូវឯកសារ ដូចខាងក្រោមឱ្យបានក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

១. ច្បាប់ថតចម្លងលិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី

២. ច្បាប់ថតចម្លងលិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ប្រការ៤.-

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមសារាចរលេខ០១៨០រថ.អប្រក.សរចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល។

ប្រការ៥.-

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំ របស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់ដំណើរការ ... ផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

ប្រការ៦.-

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ មកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

ប្រការ៧.-

ម្ចាស់ស្ថានីយ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

ប្រការ៨.-

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៩.-

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាតឱ្យបានឆាប់រហ័ស តាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

ប្រការ១០.-

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិចមុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

ប្រការ១១.-

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ.០០៣ផ.រ៉ូ.អប្រ.លអ.....ចុះថ្ងៃទី.....០៦.....ខែ.....កុម្ភៈ.....ឆ្នាំ២០២០.....របស់ក្រសួងរ៉ែនិងថាមពលនិងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះនិងបទប្បញ្ញត្តិជាធរមាន។

ប្រការ១២.-

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ) ខែឬប្រព្រឹត្តល្មើសច្បាប់ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០០៣ផ.រ៉ូ.អប្រ.លអ.ចុះថ្ងៃទី....០៦.....ខែ...កុម្ភៈ.....ឆ្នាំ២០២០....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

ប្រការ១៣.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីរអ៊ី និងថាមពលខេត្តព្រះសីហនុ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣ រោចខែ អាឍ ឆ្នាំ ជូ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

ស្នឿយ រ៉ាវ

<u>កន្លែងទទួល:</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលាខេត្តព្រះសីហនុ
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២០៧៩ ប្រក.

ប្រកាស
ស្តីពី
ការចុះឈ្មោះកុងបញ្ជីសមាគម

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងផ្ទៃបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំចុះឈ្មោះលេខ០០១ សអសអ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ របស់សមាគមជំរុញការអភិវឌ្ឍវិនិយោគទេសចរណ៍សេដ្ឋកិច្ចអាស៊ាន

សម្រេច

ប្រការ ១ ..

ត្រូវបានចុះឈ្មោះ **សមាគមជំរុញការអភិវឌ្ឍវិនិយោគទេសចរណ៍សេដ្ឋកិច្ចអាស៊ាន** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

ប្រការ ២ ..

សមាគមជំរុញការអភិវឌ្ឍវិនិយោគទេសចរណ៍សេដ្ឋកិច្ចអាស៊ាន ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

ប្រការ ៣ ..

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាន៣ក៏ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តសៀមរាប ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ..ចន្ទ..ដប់ប្រាំបី..ខែ..មេសា.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ..ខែ..ឧសភា..ឆ្នាំ២០២០
ឧបនាយករដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ស៊ុន-ហ៊ុន

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
- ឧត្តមការិយាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ដើម្បីជូនជ្រាប)
- ដូចប្រការ ៣ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២១០៥ ប្រក.

ប្រកាស
ស្តីពី
ការចុះឈ្មោះក្លិបបញ្ជីសមាគម

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំចុះឈ្មោះលេខ០០១/២០ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ របស់សមាគមមនុស្សធម៌ អ្នកអង្គ ថានុ៉ា

សម្រេច

ប្រការ ១ ..

ត្រូវបានចុះឈ្មោះ **សមាគមមនុស្សធម៌ អ្នកអង្គ ថានុ៉ា** ក្នុងបញ្ជីសមាគម នៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ៣៣E₀ ភូមិត្រពាំងថ្លឹង៤ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ប្រការ ២ ..

សមាគមមនុស្សធម៌ អ្នកអង្គ ថានុ៉ា ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុក នៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

ប្រការ ៣ ..

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ..ព្រហស្បតិ៍..ទី២៣..ខែ..ចេត្ត.....ឆ្នាំ..ឆ្លូ..ព.ស..២..ត..ណ..ត..ត..ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍
លេខ១២៧,ប្រ.ក

ថ្ងៃអង្គារ ២រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០

ប្រកាស
ស្តីពី
វិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

សម្រេច

ប្រការ ១._

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធានសុវត្ថិភាពសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍និងអ្នកបកប្រែភាសាបន្ត ដើម្បីទប់ស្កាត់ការកើតរាលដាលនៃជំងឺឆ្លងកូវីដ-១៩ លើកកម្ពស់សុវត្ថិភាពទេសចរ និងបង្កើតទំនុកចិត្តជូនទេសចរធ្វើដំណើរកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ២._

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែកាសាបន្ត។

ប្រការ ៣._

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែកាសាបន្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៤._

មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែកាសាបន្តមានកាតព្វកិច្ចអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ដូចខាងក្រោម៖

ក. ត្រូវណែនាំដល់ទេសចរជាតិ-អន្តរជាតិពីវិធានសុវត្ថិភាពរបស់ក្រសួងសុខាភិបាលស្តីពីការបង្ការ និងទប់ស្កាត់ជំងឺកូវីដ-១៩ ដោយផ្តោតលើគោលការណ៍ពាក់ម៉ាស់ លាងដៃ រាស់ករម្ដៅ និងក្សាគម្លាត មុនពេលផ្តល់សេវាកម្ម

ខ. ត្រូវពាក់របាំងការពារមុខ ឬម៉ាស់ ក្នុងអំឡុងពេលផ្តល់សេវាកម្ម

គ. ត្រូវដាក់តាមខ្លួននូវម៉ាស់ ទឹកអាល់កុល ឬទឹកសម្លាប់មេរោគ និងឧបករណ៍រាស់ករម្ដៅ(បើមាន) សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬ/និងចែកជូនទេសចរដែលជាអ្នកទទួលសេវាកម្មក្នុងករណីចាំបាច់

ឃ.ត្រូវសម្អាតដៃជាមួយទឹកអាល់កុល ឬទឹកសម្លាប់មេរោគភ្លាមរៀងរាល់ពេលដែលប៉ះពាល់ផ្ទាល់ជាមួយទេសចរ និងត្រូវសម្អាតដៃឱ្យបានញឹកញាប់

ង. ត្រូវបន្តអនុវត្តឱ្យបានត្រឹមត្រូវតាមក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈរបស់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែកាសាបន្ត

ច. ត្រូវប្រើប្រាស់ឧបករណ៍ឧក្សាសនាសព្ទ ករណីទទួលក្រុមទេសចរលើសពី១០នាក់

ឆ. ត្រូវរាយការណ៍ទៅការីទេសចរណ៍របស់ខ្លួន ឬលេខទំនាក់ទំនងទាន់ហេតុការណ៍១១៥ ក្នុងករណីសង្កេតឃើញទេសចរមានអាការដូចជា គ្រុនក្តៅ ក្អក កណ្តាស់ រលាកបំពង់ក ហៀរសំបោរ ឬពិបាកដកដង្ហើម។

ប្រការ ៥._

វិធានសុវត្ថិភាពទេសចរណ៍ដែលមានចែងក្នុងប្រការ៤នៃប្រកាសនេះ ត្រូវចាត់ទុកជាលក្ខខណ្ឌបន្ថែមក្នុងការស្នើសុំ ឬបន្តអាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ ឬបណ្ណអនុញ្ញាតអ្នកបកប្រែកាសាបន្ត។ ការមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមវិធានទាំងនេះ នឹងក្លាយជាកម្មវត្ថុនៃព្យួរអាជ្ញាបណ្ណទេសចរណ៍ ឬបណ្ណអនុញ្ញាតអ្នកបកប្រែកាសាបន្តជាបន្ទាន់ ស្របតាមមាត្រា៤៤ កថាខណ្ឌទី២នៃច្បាប់ស្តីពីទេសចរណ៍។

ប្រការ ៦._

មគ្គុទ្ទេសក៍ទេសចរណ៍ដែលបានបំពេញគ្រប់វិធានសុវត្ថិភាពទេសចរណ៍ក្នុងប្រការ៤នៃប្រកាសនេះ នឹងទទួលបានឡាបិលមគ្គុទ្ទេសក៍ទេសចរណ៍សុវត្ថិភាពដូចបានកំណត់ក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ។

អ្នកបកប្រែកាសាបន្តដែលបានបំពេញគ្រប់វិធានសុវត្ថិភាពទេសចរណ៍ក្នុងប្រការ៤នៃប្រកាសនេះនឹងទទួលបានឡាបិលអ្នកបកប្រែកាសាបន្តសុវត្ថិភាពដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។

ទ្ធាបិលមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តដែលមានសុវត្ថិភាពមានទម្រង់ជាស្លាកសញ្ញាសម្គាល់។

ប្រការ ៧._

នីតិវិធីអនុវត្តវិធានសុវត្ថិភាពសម្រាប់អាជីវកម្មមគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្តត្រូវកំណត់ដោយសេចក្ដីណែនាំរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ប្រការ ៨._

ក្រុមការងារត្រួតពិនិត្យមគ្គុទ្ទេសក៍ទេសចរណ៍រាជធានីខេត្តជាយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានសុវត្ថិភាពសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត។

ប្រការ ៩._

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ អគ្គាធិការ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

អនុលោមតាម :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីខេត្ត
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សមាគមមគ្គុទ្ទេសក៍ទេសចរណ៍
- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា
- ជ្វចប្រការ ៩
- កាដកិច្ច
- ឯកសារ គាលប្បវត្តិ

ឧបសម្ព័ន្ធ១
នៃប្រកាសលេខ ១២៨ ប្រក ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍និងអ្នកបកប្រែភាសាបន្ត

ឯកសារមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានសុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩ (COVID-19)

វិធានសុវត្ថិភាពទេសចរណ៍
TOURISM SAFETY MEASURES

ឧបសម្ព័ន្ធ២
នៃប្រកាសលេខ ១២៨ ប្រកបចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីវិធានសុវត្ថិភាពទេសចរណ៍សម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍និងអ្នកបកប្រែភាសាបន្ត

ឡាមិលអ្នកបកប្រែភាសាបន្ត ដែលមានសុវត្ថិភាពប្រឆាំងនឹងកូវីដ-១៩ (COVID-19)

វិធានសុវត្ថិភាពទេសចរណ៍
TOURISM SAFETY MEASURES

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី